**បញ្ជីហេតុការណ៍សម្រាប់អ្នកទទួលនិងអ្នកថែរទាំ**

**ការអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់(EUA) នៃវ៉ាក់សាំងហ្វាយហ្សឺ ប្បូទិចកូវីដ19 (PFIZER-BIONTECH COVID-19) ដើម្បីបង្ការជម្ងឺកូវីដ19(COVID-19)ដែលបង្ករដោយវីរុសកូរ៉ូណា សម្រាប់បុគ្គលម្នាក់ៗដែលមានអាយុចាប់ពី16ឆ្នាំឡើងទៅ**

អ្នកនឹងត្រូវបានផ្តល់វ៉ាក់សាំង Pfizer-BioNTech COVID-19 ដើម្បីបង្ការជម្ងឺ COVID-19 ដែលបង្ករដោយវីរុសសារកូវីពីរ( SARS-CoV-2) ។

បញ្ជីហេតុការណ៍នេះមានផ្ទុកព័ត៌មានដើម្បីជួយអ្នកយល់ដឹងពីហានិភ័យនិងអត្ថប្រយោជន៍នៃវ៉ាក់សាំង Pfizer-BioNTech COVID-19 ដែលអ្នកអាចនឹងទទួលបានដោយសារវាមានការរាលដាលទៅគ្រប់កន្លែងនៃជម្ងឺ COVID-19 ក្នុងពេលបច្ចុប្បន្ននេះ។

វ៉ាក់សាំង Pfizer-BioNTech COVID-19 គឺជាវ៉ាក់សាំងមួយប្រភេទហើយអាចនឹងបង្ការអ្នកមិនឲ្យកើតជម្ងឺ COVID-19 ។ វាមិនទាន់មានរដ្ឋបាលចំណីអាហារសហរដ្ឋអាមេរិកអនុម័តឲ្យប្រើប្រាស់ដើម្បីបង្ការជម្ងឺ COVID-19 នោះនៅឡើយទេ។

សូមអាននូវបញ្ជីហេតុការណ៍នេះសម្រាប់ព័ត៌មានស្តីអំពីវ៉ាក់សាំង Pfizer-BioNTech COVID-19 ។ សូមពិភាក្សាជាមួយអ្នកផ្តល់ការចាក់វ៉ាក់សាំងបង្ការរោគ ប្រសិនបើអ្នកមានសំណួរទាំងឡាយ។ វាគឺជាជម្រើសរបស់អ្នកក្នុងការជ្រើសរើសយកវ៉ាក់សាំង Pfizer-BioNTech COVID-19 ។

វ៉ាក់សាំង Pfizer-BioNTech COVID-19 ត្រូវបានគេប្រើប្រាស់ជាពីរកម្រិត(dose)បន្តបន្ទាប់គ្នាក្នុងរយៈពេលបីសប្តាហ៍ដោយឡែក ទៅក្នុងសាច់ដុំ។

វ៉ាក់សាំង Pfizer-BioNTech COVID-19 អាចនឹងមិនការពារមនុស្សគ្រប់រូបនោះទេ។

បញ្ជីហេតុការណ៍នេះអាចត្រូវបានគេធ្វើបច្ចុប្បន្ន។ សម្រាប់ព័ត៌មានថ្មីៗបំផុតនៃបញ្ជីហេតុការណ៍ សូមចូលទៅទស្សនាគេហទំព័រwww.cvdvaccine.com ។

**តើអ្វីខ្លះដែលអ្នកត្រូវដឹងមុននឹងអ្នកទទួលវ៉ាក់សាំងនេះ?**

**តើ COVID-19 ជាអ្វី?**

COVID-19 គឺជាជម្ងឺដែលបង្ករឡើងដោយវីរុសកូរ៉ូណាដែលគេហៅថា SARS-CoV-2 ។ វីរុសកូរ៉ូណាប្រភេទនេះមិនត្រូវបានគេធ្លាប់ឃើញមានពីមុនមកនោះទេ។ អ្នកអាចទទួល COVID-19 តាមរយៈការប៉ះពាល់ជាមួយមនុស្សដទៃទៀតដែលមានវីរុសនេះ។ ភាគច្រើនបំផុតគឺជម្ងឺផ្លូវដង្ហើមដែលអាចប៉ះពាល់ដល់សរីរាង្គដទៃទៀត។ មនុស្សដែលមាន COVID-19 មានរោគសញ្ញាជាច្រើនដែលត្រូវបានគេរាយការណ៍ ផ្តើមចេញពីរោគសញ្ញាល្មមៗទៅជម្ងឺធ្ងន់ធ្ងរ។ រោគសញ្ញាទាំងឡាយអាចលេចឡើងក្នុងរយៈពេលពី 2 ទៅ 14ថ្ងៃក្រោយពីការប៉ះពាល់វីរុស។ រោគសញ្ញាទាំងឡាយរួមមាន ក្តៅខ្លួនឬគ្រុនញាក់ ក្អក ពិបាកដកដង្ហើម អស់កម្លាំង ឈឺសាច់ដុំឬឈឺខ្លួន ឈឺក្បាល បាត់បង់រស់ជាតិឬខ្លិននៅពេលថ្មីៗនេះ ឈឺក តឹងច្រមុះឬហៀរសំបោរ ចង្អោរឬក្អួត និងរាគរុះជាដើម។

**តើអ្វីទៅជាវ៉ាក់សាំង Pfizer-BioNTech COVID-19?**

បានកែសម្រួល: ខែធ្នូ ឆ្នាំ2020

វ៉ាក់សាំង Pfizer-BioNTech COVID-19 គឺជាវ៉ាក់សាំងដែលមិនទាន់មានការអនុម័ត តែវាអាចបង្ការជម្ងឺ COVID-19 បាន។
វាមិនទាន់មានវ៉ាក់សាំងដែលរដ្ឋបាលចំណីអាហារសហរដ្ឋអាមេរិកអនុម័តឲ្យប្រើប្រាស់ដើម្បីបង្ការជម្ងឺ COVID-19 នោះនៅឡើយទេ។

រដ្ឋបាលចំណីអាហារសហរដ្ឋអាមេរិក(FDA)បានអនុម័តឲ្យប្រើប្រាស់ជាបន្ទាន់នៃវ៉ាក់សាំង Pfizer-BioNTech COVID-19 ដើម្បីបង្ការជម្ងឺ COVID-19 ចំពោះមនុស្សដែលមានអាយុចាប់ពី 16ឆ្នាំឡើងទៅ ក្រោមការអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់(EUA) ។

សម្រាប់ព័ត៌មានលម្អិតបន្ថែមស្តីពី EUA សូមអានផ្នែក “តើអ្វីទៅជាការអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់(EUA)? ”

ដែលនៅចុងបញ្ចប់នៃបញ្ជីហេតុការណ៍នេះ។

**តើអ្វីខ្លះដែលអ្នកគួរលើកយកមកនិយាយជាមួយអ្នកផ្តល់ការចាក់វ៉ាក់សាំងបង្ការរោគមុនពេលដែលអ្នកទទួលវ៉ាក់សាំង Pfizer-BioNTech COVID-19 នោះ?**
**សូមប្រាប់អ្នកផ្តល់ការចាក់វ៉ាក់សាំងបង្ការរោគអំពីរាល់ស្ថានភពសុខភាពរបស់អ្នក រួមទាំងរោគសញ្ញាទាំងឡាយប្រសិនបើអ្នកមាន:**

-  ប្រតិកម្មទាស់ណាមួយ
-  គ្រុនក្តៅ
-  វិបត្តិឈាមកក ឬកំពុងប្រើប្រាស់ថ្នាំឈាមកក
-  ការបាត់បង់ភាពស៊ាំទៅនឹងជម្ងឺ ឬកំពុងប្រើប្រាស់ថ្នាំដែលប៉ះពាល់ដល់ប្រព័ន្ធភាពស៊ាំរបស់អ្នក
-  ផ្ទៃពោះ ឬគ្រោងនឹងមានផ្ទៃពោះ
-  ការបំបៅកូនដោយទឹកដោះម្តាយ
-  ទទួលបានវ៉ាក់សាំង COVID-19 ដទៃទៀត

**តើអ្នកណាខ្លះដែលគួរទទួលបានវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ?**
រដ្ឋបាលចំណីអាហារសហរដ្ឋអាមេរិក(FDA)បានអនុម័តឲ្យប្រើប្រាស់ជាបន្ទាន់នៃវ៉ាក់សាំង Pfizer-BioNTech COVID-19 ចំពោះមនុស្សដែលមានអាយុចាប់ពី 16ឆ្នាំឡើងទៅ។

**តើអ្នកណាខ្លះដែលមិនគួរទទួលបានវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ?**
អ្នកមិនគួរទទួលបានវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះទេ ប្រសិនបើអ្នក:

-  មានប្រតិកម្មទាស់ធ្ងន់ធ្ងរបន្ទាប់ពីបានចាក់វ៉ាក់សាំងលើកទីមួយមក
-  មានប្រតិកម្មទាស់ធ្ងន់ធ្ងរទៅនឹងធាតុផ្សំណាមួយនៃវ៉ាក់សាំងនេះ

**តើអ្វីខ្លះជាធាតុផ្សំនៃវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ?**
វ៉ាក់សាំង PFIZER-BIONTECH COVID-19 មានធាតុផ្សំដូចតទៅនេះ: mRNA, lipids ((4-hydroxybutyl)azanediyl)bis(hexane-6,1-diyl)bis(2-hexyldecanoate), 2 [(polyethylene glycol)-2000]-N,N-ditetradecylacetamide, 1,2-Distearoyl-sn-glycero-3-phosphocholine, and cholesterol), potassium chloride, monobasic potassium phosphate, sodium chloride, dibasic sodium phosphate dihydrate, and sucrose។

**តើវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះនឹងត្រូវបានផ្តល់ជូនយ៉ាងដូចម្តេច?**
គេនឹងចាក់វ៉ាក់សាំង PFIZER-BIONTECH COVID-19 ទៅក្នុងសាច់ដុំរបស់អ្នក។

ការចាក់វ៉ាក់សាំង PFIZER-BIONTECH COVID-19 ពីរកម្រិតជាបន្តបន្ទាប់ក្នុងរយៈពេលបីសប្តាហ៍ដាច់ដោយឡែកពីគ្នា។

ប្រសិនបើអ្នកទទួលបានវ៉ាក់សាំង PFIZER-BIONTECH COVID-19 លើកទីមួយ អ្នកគួរទទួលបានវាលើកទីពីក្នុងរយៈពេលបីសប្តាហ៍ក្រោយមកដើម្បីបង្គ្រប់កម្រិតប្រើប្រាស់របស់វា។

**តើវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ ធ្លាប់បានគេប្រើប្រាស់ពីមុនមកដែរឬទេ?**
វ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះគឺជាវ៉ាក់សាំងដែលមិនទាន់អនុម័តនៅឡើយនោះទេ។ នៅក្នុងការសាកល្បងវេជ្ជសាស្ត្រ មានមនុស្សប្រមាណជា 20,000 នាក់ ដែលមានអាយុចាប់ពី16 ឆ្នាំឡើងទៅ បានទទួលយ៉ាងហោចណាស់ ចំនួនមួយកម្រិតប្រើប្រាស់នៃវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ។

**តើវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ មានអត្ថប្រយោជន៍អ្វីខ្លះ?**
នៅក្នុងការសាកល្បងវេជ្ជសាស្ត្រដែលកំពុងតែដំណើរការ វ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះបានបង្ហាញនូវការបង្ការ COVID-19 បន្ទាប់ពីបានប្រើប្រាស់វាពីរកម្រិតក្នុងរយៈពេលបីសប្តាហ៍ដោយឡែកពីគ្នា។ បច្ចុប្បន្ននេះ គេមិនទាន់បានដឹងពីរយៈពេលនៃការការពាររបស់វាប្រឆាំងនឹង COVID-19នេះនៅឡើយនោះទេ។

**តើវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ មានហានិភ័យអ្វីខ្លះ?**
ឥទ្ធិពលបន្ទាប់បន្សំដែលបានគេរាយការណ៍មកជាមួយនឹងវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះរួមមាន:

- ឈឺនៅត្រង់កន្លែងដែលចាក់
- អស់កម្លាំង
- ឈឺក្បាល
- ឈឺសាច់ដុំ
- គ្រុនញាក់
- ឈឺសន្លាក់
- គ្រុនក្តៅ
- ហើមត្រង់កន្លែងដែលចាក់
- ស្នាមក្រហមត្រង់កន្លែងដែលចាក់
- ចង់ក្អួត
- មានអារម្មណ៍ថាមិនស្រួលខ្លួន
- ហើមក្រពេញទឹករងៃ(lymphadenopathy)

វាមានឱកាសតិចតួចដែលវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះអាចបង្ករឲ្យមានប្រតិកម្មទាស់ធ្ងន់ធ្ងរ។ ប្រតិកម្មទាស់ធ្ងន់ធ្ងរ ជាធម្មតាគួរតែកើមមានឡើងក្នុងរយៈពេលពីរបីនាទីទៅមួយម៉ោង បន្ទាប់ពីទទួលបានកម្រិតប្រើប្រាស់នៃវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ។ រោគសញ្ញានៃការប្រតិកម្មទាស់ធ្ងន់ធ្ងរអាចរួមមាន:

- ពិបាកដកដង្ហើម
- ហើមមុខនិងករបស់អ្នក
- បេះដូងលោតញាប់

បានកែសម្រួល: ខែធ្នូ ឆ្នាំ2020

- ឡើងកន្ទួលជុំវិញដងខ្លួន
- វិលមុខនិងចុះខ្សោយ

រោគសញ្ញាទាំងអស់នេះអាចមិនមែនសុទ្ធតែជាឥទ្ធិពលបន្ទាប់បន្សំនៃវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ នោះទេ។
ឥទ្ធិពលបន្ទាប់បន្សំដែលមិនបានរំពឹងទុកហើយធ្ងន់ធ្ងរអាចនឹងកើតមានឡើង។ វ៉ាក់សាំង PFIZER-BIONTECH COVID-19
នេះកំពុងស្ថិតក្នុងការសិក្សាស្រាវជ្រាវនៅក្នុងការសាកល្បងវេជ្ជសាស្ត្រនៅឡើយទេ។

**តើខ្ញុំគួរធ្វើអ្វីខ្លះអំពីឥទ្ធិពលបន្ទាប់បន្សំនេះ?**
ប្រសិនបើអ្នកជួបប្រទះនឹងប្រតិកម្មទាស់ធ្ងន់ធ្ងរ សូមទូរស័ព្ទទៅកាន់លេខ 9-1-1 ឬទៅកាន់មន្ទីរពេទ្យដែលនៅជិតអ្នកបំផុត។

សូមទូរស័ព្ទទៅកាន់អ្នកផ្តល់ការចាក់វ៉ាក់សាំងបង្ការរោគ មន្ត្រីសុខាភិបាលរបស់អ្នក ប្រសិនបើអ្នកមានឥទ្ធិពលបន្ទាប់បន្សំដែលរំខានអ្នកឬដែលមិនបាត់នោះ។

**សូមរាយការណ៍ឥទ្ធិពលបន្ទាប់បន្សំនៃវ៉ាក់សាំងទៅកាន់ FDA/CDC តាមរយៈប្រព័ន្ធរាយការណ៍ព្រឹត្តិការណ៍ធ្ងន់ធ្ងរនៃវ៉ាក់សាំង(VAERS)។**
លេខទូរស័ព្ទដែលមិនគិតថ្លៃរបស់ VAERS គឺ 1-800-822-7967 ឬសូមរាយការណ៍តាមគេហទំព័រ https://vaers.hhs.gov/reportevent.html ។ សូមដាក់បញ្ចូល“Pfizer-BioNTech COVID-19 Vaccine EUA” នៅក្នុងជួរទីមួយប្រអប់លេខ18 នៃទម្រង់បែបបទរាយការណ៍។

ជាងនេះទៅទៀត
អ្នកអាចរាយការណ៍អំពីឥទ្ធិពលបន្ទាប់បសន្សំនេះទៅសាជីវកម្មឱសថពហុជាតិសហរដ្ឋអាមេរិក(Pfizer Inc)តាមព័ត៌មានទាក់ទងដែលផ្តល់ជូនដូចខាងក្រោម។

| គេហទំព័រ | លេខទូរសារ | លេខទូរស័ព្ទ |
|---|---|---|
| www.pfizersafetyreporting.com | 1-866-635-8337 | 1-800-438-1985 |

**តើវានឹងមានអ្វីកើតឡើងប្រសិនបើខ្ញុំមិនទទួលយកវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ?**
វាគឺជាជម្រើសរបស់អ្នកក្នុងការទទួលយកឬមិនទទួលយកវ៉ាក់សាំង PFIZER-BIONTECH COVID-19 នេះ។ ប្រសិនបើអ្នកសម្រេចចិត្តមិនទទួលយកវា
វានឹងមិនមានការផ្លាស់ប្តូរស្តង់ដារការព្យាបាលសុខភាពរបស់អ្នកនោះទេ។

**តើមានជម្រើសដទៃណាផ្សេងទៀតដែរឬទេ សម្រាប់បង្ការជម្ងឺ COVID-19នេះ ក្រៅពីវ៉ាក់សាំង PFIZER-BIONTECH COVID-19 នោះ?**
បច្ចុប្បន្ននេះ វាមិនទាន់មានវ៉ាក់សាំងជម្រើសណាមួយដែលបានអនុម័តដើម្បីបង្ការជម្ងឺ COVID-19។
រដ្ឋបាលចំណីអាហារសហរដ្ឋអាមេរិកអាចនឹងអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់នៃវ៉ាក់សាំងដទៃទៀតដើម្បីបង្ការជម្ងឺ COVID-19នេះ។

**តើខ្ញុំអាចទទួលវ៉ាក់សាំង PFIZER-BIONTECH COVID-19នេះ ជាមួយនឹងវ៉ាក់សាំងដទៃផ្សេងទៀតដែរឬទេ?**

បានកែសម្រួល: ខែធ្នូ ឆ្នាំ2020

វាគ្មានព័ត៌មានណាមួយស្ដីអំពីការប្រើប្រាស់វ៉ាក់សាំង PFIZER-BIONTECH COVID-19នេះ ជាមួយនឹងវ៉ាក់សាំងដទៃផ្សេងទៀតនោះទេ។

**តើនឹងមានអ្វីកើតមានឡើង ប្រសិនបើខ្ញុំកំពុងមានផ្ទៃពោះឬកំពុងបំបៅកូនដោយទឹកដោះនោះ?**
ប្រសិនបើអ្នកកំពុងមានផ្ទៃពោះឬកំពុងបំបៅកូនដោយទឹកដោះនោះ សូមពិភាក្សាជម្រើសរបស់អ្នកជាមួយនឹងអ្នកផ្ដល់សេវាសុខភាពរបស់អ្នក។

**តើវ៉ាក់សាំង PFIZER-BIONTECH COVID-19នេះនឹងធ្វើឲ្យខ្ញុំកើតជម្ងឺCOVID-19ដែរឬទេ?**
ទេ វ៉ាក់សាំង PFIZER-BIONTECH COVID-19នេះមិនមានផ្ទុកវីរុសSARS-CoV-2 និងមិនអាចធ្វើឲ្យអ្នកមានជម្ងឺCOVID-19នោះទេ។

**សូមរក្សាប័ណ្ណចាក់វ៉ាក់សាំងបង្ការរោគរបស់អ្នក**
នៅពេលដែលអ្នកទទួលបានការចាក់ថ្នាំលើកទីមួយ គេនឹងផ្ដល់ប័ណ្ណចាក់ថ្នាំបង្ការរោគមួយសន្លឹកដល់អ្នកដើម្បីឲ្យអ្នកបង្ហាញវានៅពេលដែលអ្នកត្រឡប់មកចាក់វ៉ាក់សាំង PFIZER-BIONTECH COVID-19នេះជាលើកទីពី។ ដូច្នេះសូមកុំភ្លេចយកប័ណ្ណរបស់អ្នកនៅពេលដែលអ្នកត្រឡប់មកវិញ។

**ព័ត៌មានបន្ថែម**
ប្រសិនបើអ្នកមានសំណួរ សូមរកមើលនៅតាមគេហទំព័រឬទូរស័ព្ទមកលេខដែលផ្ដល់ជូនដូចខាងក្រោមនេះ។

ដើម្បីទទួលបាននូវបញ្ជីហេតុការណ៍ថ្មីៗបំផុត សូមធ្វើការស្កេនកូដ QR ដែលបានផ្ដល់ដូចខាងក្រោមនេះ។

| **គេហទំព័រទូទៅ** | **លេខទូរស័ព្ទ** |
|---|---|
| www.cvdvaccine.com | 1-877-829-2619<br>(1-877-VAX-CO19) |

**តើខ្ញុំអាចបានដំណឹងជាបន្ថែមទៀតយ៉ាងដូចម្ដេច?**
- សូមសួរទៅអ្នកផ្ដល់ការចាក់វ៉ាក់សាំងបង្ការរោគ។
- សូមមើលCDCតាមរយៈគេហទំព័រ https://www.cdc.gov/coronavirus/2019-ncov/index.html.
- សូមមើលFDA តាមរយៈគេហទំព័រ https://www.fda.gov/emergency-preparedness-and-response/mcm-legal-regulatory-and-policy-framework/emergency-use-authorization.
- សូមទាក់ទងជាមួយនឹងផ្នែកសុខាភិបាលសាធារណៈនៅក្នុងតំបន់ឬរដ្ឋរបស់អ្នក។

**តើព័ត៌មានស្ដីពីការចាក់ថ្នាំបង្ការរោគរបស់ខ្ញុំនឹងត្រូវបានកត់ត្រាទុកនៅទីណា?**
អ្នកផ្ដល់ការចាក់វ៉ាក់សាំងបង្ការរោគអាចបញ្ចូលព័ត៌មានស្ដីពីការចាក់វ៉ាក់សាំងបង្ការរោគរបស់អ្នកនៅក្នុងប្រព័ន្ធព័ត៌មានភាពស៊ាំនៃដែនសមត្ថកិច្ចតំបន់ឬរដ្ឋរបស់អ្នក(IIS)ឬប្រព័ន្ធដទៃផ្សេងទៀតដែលបានចាត់តាំងឡើង។

បានកែសម្រួល: ខែធ្នូ ឆ្នាំ2020

នេះនឹងធ្វើឲ្យប្រាដកថាអ្នកទទួលបានវ៉ាក់សុាំងដដែលនៅពេលដែលអ្នកត្រឡប់មកចាក់កម្រឹត
ប្រើប្រាស់លើកទីពី។ សម្រាប់ព័ត៍មានលម្អិតបន្ថែមស្តីអំពី IIS សូមមើលគេហទំព័រ:
https://www.cdc.gov/vaccines/programs/iis/about.html.

**តើអ្វីទៅជាប្រតិវិធានការនៅក្នុងកម្មវិធីសំណងរបួសនោះ?**

ប្រតិវិធានការនៅក្នុងកម្មវិធីសំណងរបួស(CICP)គឺជាកម្មវិធីសហព័ន្ធមួយដែលអាចជួយចេញ
ថ្លៃព្យាបាលជម្ងឺនិងចំណាយជាក់ស្តែងផ្សេងៗទៀតនៃមនុស្សមួយចំនួនដែលបានទទួលរងគ្រោះ
ធ្ងន់ធ្ងរដោយឱសថឬវ៉ាក់សាំងបង្ការរោគមួយចំនួន រួមទាំងវ៉ាក់សាំងនេះផងដែរ។ ជាទូទៅ
ការទាមទារសំណងត្រូវដាក់ជូនឲ្យ CICP
ពិនិត្យនិងសម្រេចក្នុងរយ:ពេលមួយឆ្នាំចាប់ពីកាលបរិច្ឆេទនៃការទទួលវ៉ាក់សាំងនេះ។
ដើម្បីបានដឹងបន្ថែមអំពីកម្មវិធីនេះ សូមមើលគេហទំព័រwww.hrsa.gov/cicp/
ឬទូរស័ព្ទទៅកាន់លេខ 1-855-266-2427 ។

**តើអ្វីទៅគឺជាការអនុញ្ញាតឲ្យប្រើប្រាស់ជាបន្ទាន់(EUA)នោះ?**

រដ្ឋបាលឱសថនិងចំណីអាហារសហរដ្ឋអាមេរិក(The United States
FDA)បានអនុញ្ញាតឲ្យប្រើប្រាស់វ៉ាក់សាំង PFIZER-BIONTECH COVID-19នេះ
នៅក្រោមយន្តការអាចយកមកប្រើប្រាស់ជាបន្ទាន់ដែលគេហៅថា EUA ។ EUA
នេះត្រូវបានគាំទ្រដោយរដ្ឋមន្ត្រីសុខាភិបាលនិងសេចក្តីប្រកាសសេវាកម្មមនុស្ស(HHS)ដែលថា
កាល:ទេស:កើតមានឡើងដើម្បីផ្តល់ហេតុផលត្រឹមត្រូវនូវការប្រើប្រាស់ជាបន្ទាន់នៃឱសថនិងផ
លិតផលជីវសាស្ត្រក្នុងកំឡុងពេលនៃការរាលដាលទៅគ្រប់ទីកន្លែងនៃជម្ងឺ COVID-19 ។

វ៉ាក់សាំង PFIZER-BIONTECH COVID-19នេះ
មិនបានធ្វើការត្រួតពិនិត្យឡើងវិញដូចគ្នាទៅនឹងប្រភេទផលិតផលដែលបានទទួលការត្រួតពិ
និត្យឬអនុម័តដោយ FDAនោះទេ។ FDAអាចផ្តល់ EUA
នៅពេលដែលបានបំពេញនូវលក្ខខណ្ឌមួយចំនួន ដែលរាប់បញ្ចូលថា វាគ្មានជម្រើសការអនុម័ត
និងមានមិនគ្រប់គ្រាន់ ។ ជាងនេះទៅទៀត ការសម្រេចចិត្តរបស់ FDA
គឺផ្អែកទៅលើភស្តុតាងវិទ្យាសាស្ត្រទាំងស្រុងដែលមាន ដោយបានបង្ហាញថា
ផលិតផលនេះអាចមានប្រសិទ្ធិភាពក្នុងការបង្ការជម្ងឺ COVID-19
ក្នុងកំឡុងពេលនៃការរាលដាលទៅគ្រប់ទីកន្លែងនៃជម្ងឺ COVID-19 ហើយថា
អត្ថប្រយោជន៍ជាច្រើនដែលគេបានដឹងមានតម្លៃជាងហានិភ័យជាច្រើនដែលគេបានដឹងនៃផ
លិតផលនេះ។
លក្ខខណ្ឌទាំងអស់ត្រូវតែបានបំពេញដើម្បអនុញ្ញាតឲ្យផលិតផលត្រូវបានគេយកមកប្រើប្រាស់
ក្នុងការព្យាបាលអ្នកជម្ងឺក្នុងកំឡុងពេលនៃការរាលដាលទៅគ្រប់ទីកន្លែងនៃជម្ងឺ COVID-19
នេះ។

EUAសម្រាប់វ៉ាក់សាំង PFIZER-BIONTECH COVID-19នេះ
ចូលជាធរមានសម្រាប់រយ:ពេលនៃជម្ងឺ COVID-19 ដែលសេចក្តីប្រកាសរបស់
EUAបញ្ជាក់ថាផ្តល់ហេតុផលត្រឹមត្រូវនូវការប្រើប្រាស់ជាបន្ទាន់នៃផលិតផលទាំងនេះ
ប្រសិនបើវាមិនត្រូវបានគេបញ្ឈប់ឬលុបចោលវិញនោះទេ(បន្ទាប់ពីនោះមក
ផលិតផលអាចនឹងលែងត្រូវបានគេប្រើប្រាស់ទៀតហើយ)។

Manufactured by
Pfizer Inc., New York, NY 10017

Manufactured for
BioNTech Manufacturing GmbH
An der Goldgrube 12
55131 Mainz, Germany

LAB-1451-0.7

បានកែសម្រួល: ខែធ្នូ ឆ្នាំ2020

សូមស្កេនដើម្បីចាប់យកវា
បញ្ជីហេតុការណ៍នេះត្រូវបានផ្តល់ជូនអ្នកទទួលវ៉ាក់សាំងសម្រា
ប់កំណត់ត្រាវេជ្ជសាស្រ្តតាមប្រព័ន្ធអេឡិចត្រូនិកឬប្រព័ន្ធព័ត៌
មានភាពស៊ាំ។

កាលបរិច្ឆេទចូនផលិតផល: ខែធ្នូ ឆ្នាំ2020

រដ្ឋបាលចំណីអាហារនិងឱសថសហរដ្ឋអាមេរិក(FDA) ផ្តល់ការបកប្រែភាសានេះជាការបម្រើជូនដល់អ្នកទស្សនាអន្តរជាតិទូទៅ។ យើងសង្ឃឹមថាលោកអ្នកនឹងយល់ឃើញថាការបកប្រែនេះមានប្រយោជន៍។  ទោះជាទីភ្នាក់ងារបានព្យាយាមដើម្បីទទួលបាននូវការបកមួយដែលមិនល្អៀងពីសេចក្តីពិតតាមដែលអាចធ្វើទៅបាន ដូចដែលមាននៅក្នុងការបកស្រាយជាភាសាអង់គ្លេសក្តី យើងទទួលស្គាល់ថា ការបកប្រែភាសានេះអាចមានភាពមិនច្បាស់លាស់ត្រឹមត្រូវឬពេញលេញដូចជាភាសាអង់គ្លេសនោះទេ។ ហេតុដូច្នេះហើយ ឯកសារជាផ្លូវការនៃឯកសារនេះគឺជាឯកសារជាភាសាអង់គ្លេស។